## សម្រង់សារព័ត៌មានថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧

### ១.គេហទំព័រ ដើមអម្ពិល

### *១.កូនសត្វទោចម្កុដទី៣ បានចាប់កំណើតហើយ ក្នុងឧទ្យានអង្គរ*

ថ្ងៃពុធ, ១៩ កក្កដា ២០១៧ 14:45 ដោយ: ដើមអម្ពិល ID:019




សៀមរាប៖ គិតត្រឹមថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧នេះ សត្វទោចម្កុដចំនួន២គូ ដែលបានព្រលែង ក្នុងតំបន់អង្គរ ដោយអាជ្ញាធរជាតិអប្សរា សហការជាមួយ អង្គការសម្ព័ន្ធមិត្តសត្វព្រៃ (Wildlife Alliance) និងក្រុមហ៊ុន ខ្សែយោងអេកូទេសចរណ៍ (Angkor Zip line) បានបង្កើតកូន៣ក្បាលហើយ។

អាជ្ញាធរជាតិអប្សរា បានព្រលែងទោចម្កុដគូដំបូង នៅតំបន់ប្រាសាទតានៃ នាខែមិថុនា ឆ្នាំ២០១៣ និងមួយគូទៀត នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ នៅខ្លោងទ្វារខ្មោចខាងកើត ប្រាសាទបាយ័ន ដែលបង្កើតបានកូនមួយ កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦។ ចំណែកទោចម្កុដមួយគូ នៅម្តុំប្រាសាទតា នៃ បានបង្កើតកូន ចំនួនពីរលើក គឺកូនទីមួយជាកូនញី នៅអំឡុងខែកញ្ញា ឆ្នាំ២០១៥ និងកូនទី២លើកនេះ កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧។ តាមលោក Todd Anthony អគ្គនាយកក្រុមហ៊ុន ខ្សែយោងអេកូទេសចរណ៍ នៅក្បែរប្រាសាទតានៃ បានឱ្យដឹងថា កូនទោចម្កុដដែលទើបកើតថ្មីនេះ មានសម្បុរស តែគេមិនទាន់ដឹងថាជាញី ឬឈ្មោលនៅឡើយទេ។ លោកបញ្ជាក់ថា គេអាចនឹងដឹងភេទរបស់វាបាននៅពេលដែល វាមានអាយុប្រហែល១ឆ្នាំ។

ផ្អែកតាមរបាយការណ៍ របស់មជ្ឈមណ្ឌលស្រាវជ្រាវដីព្រៃ និងសត្វព្រៃ ក្នុងឆ្នាំ២០១៦ បានឱ្យដឹងថា ទោចម្កុដត្រូវបានចុះក្នុងបញ្ជីក្រហម របស់អង្គការអភិរក្សសត្វព្រៃពិភពលោក (IUCN) ជាប្រភេទសត្វជិតផុតពូជ។ សត្វដ៏កម្រមួយនេះ មានវត្តមាននៅលើទឹកដីកម្ពុជា មិនដល់១ម៉ឺនក្បាលទេ។

តាមការសិក្សា ជំរឿនសត្វព្រៃកន្លងមក រមណីយដ្ឋានអង្គរធ្លាប់មាន សត្វព្រៃជាច្រើនប្រភេទរស់នៅ។ ដោយឡែក សត្វព្រៃប្រភេទទោចម្កុដនេះ ក៏ធ្លាប់មានវត្តមាន ក្នុងតំបន់អង្គរផងដែរ។ ប៉ុន្តែក្នុងចន្លោះនៃសង្គ្រាមស៊ីវិលមកដល់ពេលបច្ចុប្បន្ននេះ ពួកទោចបានស្លាប់ផុតពូជ ពីព្រៃនេះទៅហើយ។ ដូចច្នេះហើយទើបនាយកដ្ឋាន គ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថានរបស់អាជ្ញាធរជាតិអប្សរា សហការជាមួយរដ្ឋបាលព្រៃឈើ និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ ធ្វើការសិក្សាស្រាវជ្រាវលម្អិតអំពីលក្ខណៈព្រៃ ដែលមានអំណោយផល ដល់ការរស់នៅរបស់ពួកសត្វទោច និងបាននាំមកព្រលែង នៅក្នុងតំបន់អង្គរនេះឡើងវិញ ដើម្បីលើកតម្លៃទេសភាពវប្បធម៌ និងធម្មជាតិក្នុងតំបន់អង្គរឲ្យកាន់តែវិសេសវិសាលថែមទៀត៕

### *២.អាជ្ញាធរជាតិអប្សរាសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តជប៉ុន បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសសង្គ្រោះបឋមដល់មន្ត្រីភ្នាក់ងារទេសចរណ៍ចំនួន៤០នាក់*

ថ្ងៃពុធ, ១៩ កក្កដា ២០១៧ 14:39 ដោយ: ដើមអម្ពិល ID:019



សៀមរាប: អាជ្ញាធរជាតិអប្សរា បានសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តជប៉ុននៃអង្គការស្រឡាញ់ ដើម្បីបើកវគ្គបណ្តុះបណ្តាលសង្គ្រោះបឋមរយៈពេលមួយថ្ងៃ ដល់មន្ត្រីភ្នាក់ងារទេសចរនៃនាយកដ្ឋានអភិវឌ្ឍន៍ទេសចរចំនួន៤០នាក់ ដែលមកពីប្រាសាទនានានៅក្នុងតំបន់អង្គរ នៅសាលសន្និសីទអង្គរ ព្រឹកថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ នេះ។

វគ្គបណ្តុះបណ្តាលសង្គ្រោះបឋមនេះ ក្រុមពេទ្យស្ម័គ្រចិត្តបានបង្រៀនផ្តោតសំខាន់ទៅលើវិធីសាស្ត្រនៃការសង្គ្រោះបឋមមនុស្សគាំងបេះដូង របៀបនៃការរុំរបួស លាងរបួស វិធីសាស្ត្រនៃការជួយមនុស្សលង់ទឹក រលាកទឹកក្តៅ និងវិធីជួយមនុស្សស្លាក់អាហារដល់មន្ត្រីភ្នាក់ងារទេសចរ ព្រោះពួកគាត់ជាអ្នកធ្វើការងារផ្ទាល់ជាមួយភ្ញៀវទេសជាតិ និងអន្តរជាតិ។

ការងារសង្គ្រោះបឋមនេះ ជាការងារបន្ថែមលើការងារស្នូលរបស់ភ្នាក់ងារទេសចរណ៍។ ការងារនេះមានសារៈសំខាន់សម្រាប់មន្ត្រីភ្នាក់ងារទេសចរណ៍ក្នុងការជួយសង្គ្រោះដល់ភ្ញៀវ ដែលជួបឧបទ្ទវហេតុណាមួយក្នុងកំឡុងពេលដែលពួកគាត់កំពុងដើរទស្សនា នៅក្នុងតំបន់រមណីយដ្ឋានអង្គរផងដែរ។

សូមបញ្ជាក់ថា នេះជាលើកទី៣ ហើយនៃវគ្គបណ្តុះបណ្តាលសង្គ្រោះបឋមដល់មន្ត្រីបុគ្គលិក ដែលធ្វើការពាក់ព័ន្ធក្នុងឧទ្យានអង្គរ ដោយវគ្គទី១ត្រូវបានរៀបចំឡើងដោយក្រុម The CPR HERO Training Center កាលពីថ្ងៃទី២៨ ខែមិថុនា ដល់ថ្ងៃទី៣ ខែកក្កដា និងលើកទី២ ពីថ្ងៃទី១៣ ខែធ្នូដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៦។

**២.គេហទំព័រ** CEN

### *១.កូនសត្វទោចម្កុដទី៣ បានចាប់កំណើតហើយ ក្នុងឧទ្យានអង្គរ*

ថ្ងៃទី 19 កក្កដា 2017, ម៉ោង 03:46:PM) | ដោយ: អាជ្ញាធរជាតិអប្សរា(CEN)




សៀមរាប៖ គិតត្រឹមថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧នេះ សត្វទោចម្កុដចំនួន២គូ ដែលបានព្រលែង ក្នុងតំបន់អង្គរ ដោយអាជ្ញាធរជាតិអប្សរា សហការជាមួយ អង្គការសម្ព័ន្ធមិត្តសត្វព្រៃ (Wildlife Alliance) និងក្រុមហ៊ុន ខ្សែយោងអេកូទេសចរណ៍ (Angkor Zip line) បានបង្កើតកូន៣ក្បាលហើយ។

អាជ្ញាធរជាតិអប្សរា បានព្រលែងទោចម្កុដគូដំបូង នៅតំបន់

ប្រាសាទតានៃ នាខែមិថុនា ឆ្នាំ២០១៣ និងមួយគូទៀត នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ នៅខ្លោងទ្វារខ្មោចខាងកើត ប្រាសាទបាយ័ន ដែលបង្កើតបានកូនមួយ កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦។ ចំណែកទោចមុដមួយគូ នៅមុំប្រាសាទតា នៃ បានបង្កើតកូន ចំនួនពីរលើក គឺកូនទីមួយជាកូនញី នៅអំឡុងខែកញ្ញា ឆ្នាំ២០១៥ និងកូនទី២លើកនេះ កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧។ តាមលោក Todd Anthony អគ្គនាយកក្រុមហ៊ុន ខ្សែយោងអេកូទេសចរណ៍ នៅក្បែរប្រាសាទតានៃ បានឱ្យដឹងថា កូនទោចមុដដែលទើបកើតថ្មីនេះ មានសម្បុរស តែគេមិនទាន់ដឹងថាជាញី ឬឈ្មោល នៅឡើយទេ។ លោកបញ្ជាក់ថា គេអាចនឹងដឹងភេទរបស់វាបាននៅពេលដែល វាមានអាយុប្រហែល១ឆ្នាំ។

ផ្អែកតាមរបាយការណ៍ របស់មជ្ឈមណ្ឌលស្រាវជ្រាវដីព្រៃ និងសត្វព្រៃ ក្នុងឆ្នាំ២០១៦ បានឱ្យដឹងថា ទោចមុដត្រូវបានចុះក្នុងបញ្ជីក្រហម របស់អង្គការអភិរក្សសត្វព្រៃពិភពលោក (IUCN) ជាប្រភេទសត្វជិតផុតពូជ។ សត្វដ៏កម្រមួយនេះ មានវត្តមាននៅលើទឹកដីកម្ពុជា មិនដល់១ម៉ឺនក្បាលទេ។

តាមការសិក្សា ជំរឿនសត្វព្រៃកន្លងមក រមណីយដ្ឋានអង្គរធ្លាប់មាន សត្វព្រៃជាច្រើនប្រភេទរស់នៅ។ ដោយឡែក សត្វព្រៃប្រភេទទោចមុដនេះ ក៏ធ្លាប់មានវត្តមាន ក្នុងតំបន់អង្គរផងដែរ។ ប៉ុន្តែក្នុងចន្លោះនៃសង្គ្រាមស៊ីវិលមកដល់ពេលបច្ចុប្បន្ននេះ ពួកទោចបានស្លាប់ផុតពូជ ពីព្រៃនេះទៅហើយ។ ដូចច្នេះហើយទើបនាយកដ្ឋាន គ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថានរបស់អាជ្ញាធរជាតិអប្សរា សហការជាមួយរដ្ឋបាលព្រៃឈើ និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ ធ្វើការសិក្សាស្រាវជ្រាវលម្អិតអំពីលក្ខណៈព្រៃ ដែលមានអំណោយផល ដល់ការរស់នៅរបស់ពួកសត្វទោច និងបាននាំមកព្រលែង នៅក្នុងតំបន់អង្គរនេះឡើងវិញ ដើម្បីលើកតម្លៃទេសភាពវប្បធម៌ និងធម្មជាតិក្នុងតំបន់អង្គរឲ្យកាន់តែវិសេសវិសាលថែមទៀត៕

## ***២.អាជ្ញាធរជាតិអប្សរាសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តជប៉ុន បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសសង្គ្រោះបឋមដល់មន្ត្រីភ្នាក់ងារទេសចរណ៍ចំនួន៤០នាក់***

(ថ្ងៃទី 19 កក្កដា 2017, ម៉ោង 03:45:PM) | ដោយ: អាជ្ញាធរជាតិអប្សរា CEN



សៀមរាប: អាជ្ញាធរជាតិអប្សរា បានសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តជប៉ុននៃអង្គការស្រឡាញ់ ដើម្បីបើកវគ្គបណ្តុះបណ្តាលសង្គ្រោះបឋមរយៈពេលមួយថ្ងៃ ដល់មន្ត្រីភ្នាក់ងារទេសចរនៃនាយកដ្ឋានអភិវឌ្ឍន៍ទេសចរចំនួន៤០នាក់ ដែលមកពីប្រាសាទនានានៅក្នុងតំបន់អង្គរ នៅសាលសន្និសីទអង្គរ ព្រឹកថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ នេះ។

វគ្គបណ្តុះបណ្តាលសង្គ្រោះបឋមនេះ ក្រុមពេទ្យស្ម័គ្រចិត្តបានបង្រៀនផ្តោតសំខាន់ទៅលើវិធីសាស្ត្រនៃការសង្គ្រោះបឋមមនុស្សគាំងបេះដូង របៀបនៃការរុំរបួស លាងរបួស វិធីសាស្ត្រនៃការជួយ

មនុស្សលង់ទឹក រលាកទឹកក្តៅ និងវិធីជួយមនុស្សស្លាក់អាហារដល់មន្ត្រីភ្នាក់ងារទេសចរ ព្រោះពួកគាត់ជាអ្នកធ្វើការងារផ្ទាល់ជាមួយភ្ញៀវទេសជាតិ និងអន្តរជាតិ។
ការងារសង្គ្រោះបឋមនេះ ជាការងារបន្ថែមលើការងារស្នូលរបស់ភ្នាក់ងារទេសចរណ៍។ ការងារនេះមានសារៈសំខាន់សម្រាប់មន្ត្រីភ្នាក់ងារទេសចរណ៍ក្នុងការជួយសង្គ្រោះដល់ភ្ញៀវ ដែលជួបឧបទ្ទវហេតុណាមួយក្នុងកំឡុងពេលដែលពួកគាត់កំពុងដើរទស្សនា នៅក្នុងតំបន់រមណីយដ្ឋានអង្គរផងដែរ។
សូមបញ្ជាក់ថា នេះជាលើកទី៣ ហើយនៃវគ្គបណ្តុះបណ្តាលសង្គ្រោះបឋមដល់មន្ត្រីបុគ្គលិក ដែលធ្វើការពាក់ព័ន្ធក្នុងឧទ្យានអង្គរ ដោយវគ្គទី១ត្រូវបានរៀបចំឡើងដោយក្រុម The CPR HERO Training Center កាលពីថ្ងៃទី២៨ ខែមិថុនា ដល់ថ្ងៃទី៣ ខែកក្កដា និងលើកទី២ ពីថ្ងៃទី១៣ ខែធ្នូដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៦៕